**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០០២ សហវ.ប្រក

# ប្រកាស

## ស្តីពី

## វិធាន និងនីតិវិធីលម្អិត នៃការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងធានាការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅកំណត់នូវវិធាន និងនីតិវិធីលម្អិតនៃការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និង នីតិបុគ្គលសាធារណៈ។

**ប្រការ៤.-**

ក្នុងក្របខ័ណ្ឌនៃប្រកាសនេះ និយមន័យនៃបច្ចេកស័ព្ទត្រូវបានកំណត់ដូចខាងក្រោម÷

- **អគារ** សំដៅដល់សំណង់ទាំងឡាយណាដែលសាងសង់ឡើងអំពី ឈើ ថ្ម ដែក កញ្ចក់ ឬទ្រង់ទ្រាយណាមួយមានលក្ខណៈប្រហាក់ប្រហែលជាលំនៅឋានជាកម្មសិទ្ធិរបស់រដ្ឋ ដែលមានពីមុនមក ឬបានសាងសង់ឡើងដោយប្រើប្រាស់ថវិការដ្ឋ ឬជំនួយពីសប្បុរសជនទាំងឡាយ និងជំនួយផ្សេងៗទៀត សម្រាប់បំរើផលប្រយោជន៍ជាតិ និងផលប្រយោជន៍សាធារណៈ។
- **បរិក្ខារបច្ចេកទេស និងឧស្សាហកម្ម** សំដៅដល់ម៉ាស៊ីនភ្លើងដែលមានកម្លាំងចាប់ពី ១១0KWA ឡើង ឬឧបករណ៍បច្ចេកទេសធំៗដែលខុសពី យានយន្ត គ្រឿងចក្រ សម្ភារៈនិងសង្ហារិម។
- **យានយន្ត** សំដៅដល់យានគ្រប់ប្រភេទដែលធ្វើចរាចរណ៍ដោយម៉ាស៊ីន ឬសម្រាប់សណ្តោង ឬ ត្រូវគេសណ្តោងទោះមាន ឬ គ្មានម៉ាស៊ីនដែលមានជាអាទិ៍÷ ទោចក្រយានយន្ត ត្រីចក្រយានយន្ត ជលយានយន្ត និងរថយន្តគ្រប់ប្រភេទ។
- **គ្រឿងចក្រ** សំដៅដល់មធ្យោបាយ និងគ្រឿងម៉ាស៊ីន ដែលមានជាអាទិ៍÷ ម៉ាស៊ីនស្ទូច ត្រាក់ទ័រ គ្រឿងចក្រទេពកោសល្យស៊ីវិល និងមធ្យោបាយម៉ាស៊ីនអូសទាញដទៃទៀត។

- **សម្ភារៈ និងសង្ហារិម** សំដៅដល់ទ្រព្យសម្បត្តិរបស់រដ្ឋ ដែលមានជាអាទិ៍÷ តុ ទូ កៅអី សាឡុង សម្ភារៈបរិក្ខារអេឡិចត្រូនិច និងព័ត៌មានវិទ្យា ព្រមទាំងសម្ភារៈនិងសង្ហារិមដទៃទៀត។
- **ទ្រព្យសម្បត្តិរដ្ឋដទៃទៀត** សំដៅដល់ទ្រព្យស្បត្តិរដ្ឋដែលក្រៅពីទ្រព្យសម្បត្តិរដ្ឋដែលមានចំណាត់ថ្នាក់ចែងក្នុងប្រការ១១ នៃប្រកាសនេះ។
- **ការជម្រះទ្រព្យសម្បត្តិរដ្ឋ** សំដៅដល់ការដកចេញពីបញ្ជីសារពើភណ្ឌនូវឈ្មោះ និងចំនួន ព្រមទាំងតម្លៃទ្រព្យសម្បត្តិទាំងឡាយរបស់រដ្ឋ ដែលបានបំពេញតាមនីតិវិធីជាធរមានរួចរាល់។
- **ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះ** សំដៅទៅលើទ្រព្យសម្បត្តិរដ្ឋដែលមានចែងក្នុងប្រការ ១២ នៃប្រកាសនេះ។

## ជំពូកទី២

## គោលការណ៍ និងការគ្រប់គ្រង

### ផ្នែកទី១

### គោលការណ៍រួម

**ប្រការ៥.–**

គ្រប់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងនីតិបុគ្គលសាធារណៈ ត្រូវរៀបចំគម្រោងជម្រះបញ្ជីប្រចាំឆ្នាំ នូវទ្រព្យសម្បត្តិរដ្ឋទាំងឡាយណាដែលជាកម្មវត្ថុនៃការស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ហើយត្រូវបានអនុញ្ញាតឱ្យជម្រះបានតែមួយដងគត់ក្នុងមួយឆ្នាំ។ គម្រោងជម្រះបញ្ជីប្រចាំឆ្នាំត្រូវមានបញ្ជាក់ព័ត៌មាននៃទ្រព្យសម្បត្តិរដ្ឋនោះ ដូចខាងក្រោម÷

- យថាប្រភេទនៃទ្រព្យសម្បត្តិរដ្ឋ
- ស្ថានភាពនៃទ្រព្យសម្បត្តិរដ្ឋ
- ការកំណត់តម្លៃនៃទ្រព្យសម្បត្តិរដ្ឋ ត្រូវយកតម្លៃដែលបានកត់ត្រាក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងតម្លៃប៉ាន់ស្មាន ដោយអង្គភាពប្រើប្រាស់ និង
- ព័ត៌មានផ្សេងទៀតដែលមានលម្អិតក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រតិទិននៃការលើកគម្រោងជម្រះបញ្ជីប្រចាំឆ្នាំ ត្រូវបានកំណត់ដូចខាងក្រោម÷**

- គ្រប់អង្គភាពប្រើប្រាស់ ត្រូវរៀបចំគម្រោងជម្រះបញ្ជីប្រចាំឆ្នាំ (N+1) មកអាជ្ញាធរកាន់កាប់យ៉ាងយូរត្រឹមត្រីមាសទី១ នៃឆ្នាំ (N)
- បន្ទាប់មកអាជ្ញាធរកាន់កាប់ ត្រូវផ្ញើគម្រោងជម្រះបញ្ជីប្រចាំឆ្នាំ (N+1)នេះ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាអាជ្ញាធរគ្រប់គ្រងយ៉ាងយូរត្រឹមខែឧសភា នៃឆ្នាំ (N) ដើម្បីរៀបចំកិច្ចដំណើរការនីតិវិធីជម្រះទ្រព្យសម្បត្តិរដ្ឋនេះ
- អាជ្ញាធរគ្រប់គ្រង ត្រូវពិនិត្យនិងសម្រេចជាគោលការណ៍លើគម្រោងស្នើសុំជម្រះទ្រព្យសម្បត្តិរដ្ឋ យ៉ាងយូរត្រឹមខែមិថុនា នៃឆ្នាំ (N)។

**ប្រការ៦.-**

ទ្រព្យសម្បត្តិរដ្ឋដែលអនុញ្ញាតឱ្យជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋបាន លុះត្រាតែទ្រព្យសម្បត្តិរដ្ឋនោះត្រូវបានចុះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរួចរាល់តាមនីតិវិធីជាធរមាន និងមានក្នុងគម្រោងជម្រះបញ្ជីប្រចាំឆ្នាំ ដែលបានទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៧.-**

ទ្រព្យសម្បត្តិរដ្ឋ ជាដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ ត្រូវបានអនុញ្ញាតឱ្យជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋបាន លុះត្រាតែបានបំពេញនីតិវិធីចប់សព្វគ្រប់ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន និងមានការសម្រេចរបស់រាជរដ្ឋាភិបាល។

## ផ្នែកទី២

## ការគ្រប់គ្រងរបស់ស្ថាប័ន

**ប្រការ៨.-**

អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ជាអ្នកសម្រេចលើសំណើសុំជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ របស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ។

**ប្រការ៩.-**

អាជ្ញាធរកាន់កាប់ មានសិទ្ធិសម្រេចលើការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋចំពោះសម្ភារៈ និងសង្ហារិម រួមមាន តុ ទូ កៅអី គ្រឿងអេឡិចត្រូនិច កង្ហារ និងកង់ធម្មតា ដែលជាទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះ ដោយមិនរួមបញ្ចូលនូវគ្រឿងសង្ហារិមប្រណិត ដែលមានតម្លៃដើមចាប់ពី ៤លានរៀលឡើង ឬមានតម្លៃខ្ពស់ឡើយ ព្រមទាំងពិនិត្យនិងវាយតម្លៃលក់ទ្រព្យសម្បត្តិរដ្ឋ ដើម្បីជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពប្រើប្រាស់របស់ខ្លួន។ ក្នុងករណីនៅសល់តម្លៃត្រូវអនុវត្តតាមនីតិវិធីហិរញ្ញវត្ថុដូចមានចែងក្នុងប្រកាសនេះ។

**ប្រការ១០.-**

គ្រប់អង្គភាពប្រើប្រាស់ ត្រូវលើកសំណើសុំជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះ មកអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋរបស់ខ្លួន ដើម្បីស្នើសុំការពិនិត្យ និងសម្រេចរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

## ជំពូកទី៣

## នីតិវិធីនៃការជម្រះ និងការលក់ទ្រព្យសម្បត្តិរដ្ឋ

## ផ្នែកទី១

## ប្រភេទ និងលក្ខខណ្ឌនៃការជម្រះទ្រព្យសម្បត្តិរដ្ឋ

**ប្រការ១១.-**

ប្រភេទនៃទ្រព្យសម្បត្តិរដ្ឋដែលអាចជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ មានដូចខាងក្រោម÷

- ដី និងអគារ
- បរិក្ខារបច្ចេកទេស និងឧស្សាហកម្ម

- យានយន្ត និងគ្រឿងចក្រ
- សម្ភារៈ និងសង្ហារិម
- ទ្រព្យសម្បត្តិរដ្ឋដទៃទៀត។

**ប្រការ១២.–**

ប្រភេទទ្រព្យសម្បត្តិរដ្ឋដូចមានចែងក្នុងប្រការ១១ ខាងលើនេះ ក្រៅពីដី ដែលជាកម្មវត្ថុនៃការអនុញ្ញាតឱ្យជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋបាន លុះត្រាតែទ្រព្យសម្បត្តិរដ្ឋទាំងនោះ មានស្ថានភាព ចាស់ទ្រុឌទ្រោមប្រើប្រាស់លែងកើត ខូចខាតធ្ងន់ធ្ងរ បាត់បង់ ឬ ខូចខាតធ្ងន់ធ្ងរ បាត់បង់ ដោយមូលហេតុប្រធានស័ក្តិ ឬ ជាការផ្ទេរការប្រើប្រាស់រវាងក្រសួង ស្ថាប័នពាក់ព័ន្ធ។ ក្នុងករណីទ្រព្យសម្បត្តិរដ្ឋទាំងនោះនៅមានតម្លៃលក់បាន ត្រូវអនុវត្តតាមនីតិវិធី ដូចមានចែងក្នុងប្រកាសនេះ។

ចំពោះការជម្រះទ្រព្យសម្បត្តិរដ្ឋជាដី ដែលបណ្តាលមកពីការលក់ ដូរ ផ្ទេរ ប្រទានកម្ម ប្រែប្រួលទំហំផ្ទៃក្រឡាដី កត់ត្រាស្ទួន ឬ ការបាត់បង់ដោយប្រការដទៃទៀត ដោយបានបំពេញនីតិវិធីបានចប់សព្វគ្រប់ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវលើកសំណើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌ មកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

## ផ្នែកទី២

## ការបង្កើតគណៈកម្មការជម្រះនិងលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះ

**ប្រការ១៣.–**

អាជ្ញាធរកាន់កាប់ ត្រូវរៀបចំបង្កើតគណៈកម្មការដើម្បីបំពេញនីតិវិធីជម្រះ និងលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះ។

**ប្រការ១៤.–**

គណៈកម្មការក្រសួង-ស្ថាប័ន មានសមាសភាពដូចខាងក្រោម÷

| | |
|---|---|
| - ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ឬតំណាង | ប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| - ប្រធានអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ | អនុប្រធាន និងជាលេខាធិការ |
| - ប្រធានអង្គភាពប្រើប្រាស់ពាក់ព័ន្ធ | សមាជិក។ |

គណៈកម្មការនេះ ត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់ក្រសួង ឬ ប្រធានស្ថាប័ន។

គណៈកម្មការនេះ មានតួនាទីនិងភារកិច្ច លើការកំណត់តម្លៃមូលដ្ឋាន និងដំណើរការដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ សម្រាប់ការជម្រះទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះរបស់អង្គភាពប្រើប្រាស់ថ្នាក់កណ្តាល និង ថ្នាក់មូលដ្ឋាន។

គណៈកម្មការនេះ ត្រូវដំណើរការដេញថ្លៃ ឬ ចរចាពិគ្រោះថ្លៃ ដោយត្រូវប្រព្រឹត្តទៅនៅទីស្តីការក្រសួង ឬស្ថាប័នសាមី។

**ប្រការ១៥.–**

គណៈកម្មការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានសមាសភាព ដូចខាងក្រោម÷

| | |
|---|---|
| - អភិបាល ឬ អភិបាលរងរាជធានី ខេត្ត | ប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |

- ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន និងជាលេខាធិការ
- តំណាងក្រសួងមហាផ្ទៃ សមាជិក
- ប្រធានអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរាជធានី ខេត្ត សមាជិក
- តំណាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ពាក់ព័ន្ធ សមាជិក
- ប្រធានអង្គភាពប្រើប្រាស់ពាក់ព័ន្ធ សមាជិក។

គណៈកម្មការនេះ ត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់គណៈអភិបាលរាជធានី ខេត្ត។

គណៈកម្មការនេះ មានតួនាទីនិងភារកិច្ច លើការកំណត់តម្លៃមូលដ្ឋាន និងដំណើរការដេញថ្លៃ ឬចរចាពិគ្រោះថ្លៃសម្រាប់ការជម្រះទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះរបស់អង្គភាពប្រើប្រាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

គណៈកម្មការនេះ ត្រូវដំណើរការដេញថ្លៃ ឬ ចរចាពិគ្រោះថ្លៃ ដោយត្រូវប្រព្រឹត្តទៅនៅរដ្ឋបាលរាជធានី ខេត្ត ពាក់ព័ន្ធ។

**ប្រការ១៦.‒**

គណៈកម្មការរបស់នីតិបុគ្គលសាធារណៈ មានសមាសភាព ដូចខាងក្រោម÷

- នាយកប្រតិបត្តិនៃនីតិបុគ្គលសាធារណៈ ប្រធាន
- តំណាងក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ អនុប្រធាន
- តំណាងក្រសួងអាណាព្យាបាលបច្ចេកទេស សមាជិក
- ប្រធានអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុពាក់ព័ន្ធ សមាជិក។

គណៈកម្មការនេះ ត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់នាយកប្រតិបត្តិ ដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល។

គណៈកម្មការនេះ មានតួនាទីនិងភារកិច្ច លើការកំណត់តម្លៃមូលដ្ឋាន និងដំណើរការដេញថ្លៃ ឬចរចាពិគ្រោះថ្លៃសម្រាប់ការជម្រះទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះរបស់អង្គភាពប្រើប្រាស់របស់នីតិបុគ្គលសាធារណៈ។

គណៈកម្មការនេះ ត្រូវដំណើរការដេញថ្លៃ ឬ ចរចាពិគ្រោះថ្លៃ ដោយត្រូវប្រព្រឹត្តទៅនៅទីតាំងរបស់នីតិបុគ្គលសាធារណៈនីមួយៗ។

## ផ្នែកទី៣
## នីតិវិធីនៃការដេញថ្លៃ និង ចរចាពិគ្រោះថ្លៃ

**ប្រការ ១៧.‒**

ការជម្រះ និងលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះ ត្រូវរៀបចំឡើងក្រោមរូបភាពនៃការដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ។

ផ្អែកតាមសំណើរបស់អង្គភាពប្រើប្រាស់ គណៈកម្មការចម្រុះ ត្រូវចុះពិនិត្យ និងវាយតម្លៃជាក់ស្តែង រួចលើកជាយោបល់ស្នើសុំប្រធានគណៈកម្មការពិនិត្យនិងសម្រេចកំណត់តម្លៃមូលដ្ឋាន ដើម្បីយកទៅអនុវត្តនីតិវិធីដេញថ្លៃ ឬ ចរចាពិគ្រោះថ្លៃ។

**ប្រការ ១៨._**

ទ្រព្យសម្បត្តិរដ្ឋទាំងអស់ដែលស្នើសុំជម្រះ ដែលទទួលបានគោលការណ៍អនុញ្ញាតឱ្យជម្រះ ត្រូវលក់ដោយដេញថ្លៃជាសាធារណៈ។

នីតិវិធីនៃការដាក់លក់ដេញថ្លៃជាសាធារណៈ រួមមានដូចតទៅ÷

១. ផ្សព្វផ្សាយ ដោយបញ្ជាក់ពី ចំនួន និងតម្លៃទ្រព្យសម្បត្តិ ទីកន្លែងលក់-ទទួលពាក្យ កាលបរិច្ឆេទចាប់ផ្ដើមលក់-ទទួលពាក្យ និងកាលបរិច្ឆេទនៃការដេញថ្លៃ។ ការផ្សព្វផ្សាយលក់ដេញថ្លៃអាចធ្វើការប្រកាសចំនួន ៣ លើក (បីលើក) ក្នុងករណី មួយលើកៗ គ្មានបេក្ខជនចូលរួមទេនោះ ត្រូវបញ្ចុះតម្លៃ ១០% នៃតម្លៃមូលដ្ឋានដែលបានប្រកាសក្នុងមួយលើកៗ។

២. គណៈកម្មការត្រូវទុករយៈពេល ៧ថ្ងៃ (ប្រាំពីរថ្ងៃ) ក្នុងការពិនិត្យឯកសារនិងលក្ខខណ្ឌផ្សេងៗរបស់បេក្ខជនមុននឹង សម្រេចទទួលយកបេក្ខជនឱ្យចូលរួមដេញថ្លៃបាន។

៣. បន្ទាប់ពីការដេញថ្លៃរួចរាល់ គណៈកម្មការ ត្រូវរៀបចំកំណត់ហេតុរួមស្តីពីលទ្ធផលនៃការដេញថ្លៃ ដោយមានសមាសភាពពីគ្រប់ភាគីពាក់ព័ន្ធ និងចុះហត្ថលេខារួមគ្នាលើកំណត់ហេតុនោះ។

**ប្រការ ១៩._**

ទ្រព្យសម្បត្តិរដ្ឋទាំងអស់ជាកម្មវត្ថុនៃការសុំជម្រះ ដែលទទួលបានគោលការណ៍អនុញ្ញាតឱ្យជម្រះ និងអាចដាក់ចរចាពិគ្រោះថ្លៃទៅបាន ក្នុងករណីណាមួយដូចខាងក្រោម÷

១. បើការដេញថ្លៃមិនទទួលបានលទ្ធផល។

២. គ្មាន ឬមានរូបវន្តបុគ្គល ឬនីតិបុគ្គលស្នើសុំចូលរួមដេញថ្លៃតែមួយ។

**ប្រការ ២០._**

នីតិវិធីនៃការចរចាពិគ្រោះថ្លៃ ត្រូវអនុវត្តដូចខាងក្រោម÷

១. ផ្សព្វផ្សាយ ដោយបញ្ជាក់ពី ចំនួន និងតម្លៃទ្រព្យសម្បត្តិ ទីកន្លែងលក់-ទទួលពាក្យ កាលបរិច្ឆេទចាប់ផ្ដើមលក់-ទទួលពាក្យ និងកាលបរិច្ឆេទនៃការចរចាពិគ្រោះថ្លៃ។ ការផ្សព្វផ្សាយលក់ចរចាពិគ្រោះថ្លៃអាចធ្វើការប្រកាសចំនួន ៣ លើក (បីលើក) ក្នុងករណីមួយលើកៗ ដោយយកតម្លៃមូលដ្ឋាននៃការផ្សព្វផ្សាយលក់ដេញថ្លៃលើកទី៣ មកធ្វើជាតម្លៃមូលដ្ឋានផ្សព្វផ្សាយលក់ចរចាពិគ្រោះថ្លៃលើកទី១។ ករណីគ្មានបេក្ខជនចូលរួមទេនោះ ត្រូវបញ្ចុះតម្លៃ ១០% នៃតម្លៃមូលដ្ឋាន ដែលបានប្រកាសក្នុងមួយលើកៗ។

២. គណៈកម្មការត្រូវទុករយៈពេល ៧ ថ្ងៃ (ប្រាំពីរថ្ងៃ) ក្នុងការពិនិត្យឯកសារនិងលក្ខខណ្ឌផ្សេងៗរបស់បេក្ខជនមុននឹង សម្រេចទទួលយកបេក្ខជនឱ្យចូលរួមចរចាពិគ្រោះថ្លៃបាន។

៣. បន្ទាប់ពីការចរចាពិគ្រោះថ្លៃ គណៈកម្មការ ត្រូវរៀបចំកំណត់ហេតុរួមស្តីពីលទ្ធផលនៃការចរចាពិគ្រោះថ្លៃ ដោយមានសមាសភាពពីគ្រប់ភាគីពាក់ព័ន្ធ និងចុះហត្ថលេខារួមគ្នាលើកំណត់ហេតុនោះ។

## ផ្នែកទី៤
## ភារកិច្ចក្រោយដេញថ្លៃ ឬ ចរចាពិគ្រោះថ្លៃលក់ជាសាធារណៈ

**ប្រការ ២១.–**

ផ្អែកលើលទ្ធផលនៃការដេញថ្លៃ ឬ ចរចាពិគ្រោះថ្លៃ គណៈកម្មការ ត្រូវលើកសំណើស្តីពីលទ្ធផលនៃការដេញថ្លៃ ឬចរចាពិគ្រោះថ្លៃនោះមកអាជ្ញាធរកាន់កាប់ ដើម្បីស្នើសុំមកអាជ្ញាធរគ្រប់គ្រង ដើម្បីពិនិត្យ និងសម្រេច។ អាជ្ញាធរគ្រប់គ្រង ត្រូវចេញលិខិតឆ្លើយតបជាគោលការណ៍យ៉ាងយូរក្នុងរយៈពេល ១ខែ។

បន្ទាប់ពីមានការឯកភាពរបស់អាជ្ញាធរគ្រប់គ្រង អាជ្ញាធរកាន់កាប់ ត្រូវកំណត់ឱ្យបេក្ខជនជ័យលាភីត្រូវទទួលបន្ទុកអនុវត្តកាតព្វកិច្ចបង់ប្រាក់ ដើម្បីប្រគល់-ទទួលទ្រព្យសម្បត្តិ ដូចមានចែងក្នុងសៀវភៅបន្ទុក។

**ប្រការ ២២.–**

ថវិកាដែលបានពីការលក់ដេញថ្លៃ ឬ ចរចាពិគ្រោះថ្លៃ ត្រូវបង់ចូលថវិការដ្ឋ ឬមានការសម្រេចដោយឡែករបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ដោយឡែកថវិកាដែលបានពីការលក់ដេញថ្លៃ ឬ ចរចាពិគ្រោះថ្លៃ របស់នីតិបុគ្គលសាធារណៈ ត្រូវបង់ចូលជាថវិការបស់នីតិបុគ្គលសាធារណៈនោះ។

**ប្រការ ២៣ .–**

បន្ទាប់ពីអនុវត្តនីតិវិធីរួចរាល់ចប់ជាស្ថាពរ អាជ្ញាធរកាន់កាប់ ត្រូវលុបទ្រព្យសម្បត្តិនោះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពប្រើប្រាស់របស់ខ្លួន។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ ២៤.–**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រកាសនេះ មានឧបសម្ព័ន្ធចំនួន ៧ (ប្រាំពីរ) ដូចខាងក្រោម÷

- ឧបសម្ព័ន្ធទី១÷ គំរូសេចក្តីជូនដំណឹងស្តីពីការប្រកាសដេញថ្លៃ និងចរចាពិគ្រោះថ្លៃ
- ឧបសម្ព័ន្ធទី២÷ គំរូពាក្យស្នើសុំចូលរួមដេញថ្លៃ និងចរចាពិគ្រោះថ្លៃ
- ឧបសម្ព័ន្ធទី៣÷ គំរូសៀវភៅបន្ទុកស្តីពីការដេញថ្លៃ និងចរចាពិគ្រោះថ្លៃ
- ឧបសម្ព័ន្ធទី៤÷ គំរូកិច្ចសន្យាអនុវត្តសៀវភៅបន្ទុកស្តីពីការដេញថ្លៃ និងចរចាពិគ្រោះថ្លៃ
- ឧបសម្ព័ន្ធទី៥÷ គំរូលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ និងចរចាពិគ្រោះថ្លៃ
- ឧបសម្ព័ន្ធទី៦÷ គំរូលិខិតអះអាងប្រគល់ប្រាក់កក់ធានាការដេញថ្លៃ និងចរចាពិគ្រោះថ្លៃ
- ឧបសម្ព័ន្ធទី៧÷ គំរូកំណត់ហេតុស្តីពីលទ្ធផលនៃការដេញថ្លៃ និងចរចាពិគ្រោះថ្លៃ។

**ប្រការ ២៥.–**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងនីតិបុគ្គលសាធារណៈត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ១២ កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- ដូចប្រការ២៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១÷ គំរូសេចក្តីជូនដំណឹងស្តីពីការប្រកាសដេញថ្លៃ និងចរចាពិគ្រោះថ្លៃ 
ភ្ជាប់នឹងប្រកាសលេខ០០៦៨សហវ.ប្រកចុះថ្ងៃទី...០៦.... ខែ..មករា. ឆ្នាំ២០២០
ស្តីពី វិធាននិងនីតិវិធីលម្អិត នៃការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

## សេចក្តីជូនដំណឹង

## ស្តីពីការប្រកាសដេញថ្លៃទ្រព្យសម្បត្តិ(.........) ដែលត្រូវបានការអនុញ្ញាតជម្រះចេញពីបញ្ជីទ្រព្យសម្បត្តិរដ្ឋ

គណៈកម្មការជម្រះនិងលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះនៃ.........មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន មេត្តាជ្រាបថា គណៈកម្មការ នឹងធ្វើការដាក់លក់ដេញថ្លៃជាកញ្ចប់ នូវ........................ (យថាប្រភេទនៃ.................................មានបញ្ជាក់លម្អិតក្នុងតារាងភ្ជាប់) ដែលត្រូវបានជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ។

រូបវន្តបុគ្គល និងនីតិបុគ្គលទាំងអស់ អាចចូលរួមដេញថ្លៃបានដោយត្រូវបំពេញសំណុំបែបបទ និងលក្ខខណ្ឌដូចមានចែងក្នុងសៀវភៅបន្ទុកដេញថ្លៃ។

តម្លៃមូលដ្ឋាន និងកាលបរិច្ឆេទនៃដំណើរការដេញថ្លៃមានដូចខាងក្រោម÷

| តម្លៃមូលដ្ឋាន | កាលបរិច្ឆេទ លក់ និង ទទួលពាក្យសុំ | កាលបរិច្ឆេទឈប់ ទទួលពាក្យសុំ | កាលបរិច្ឆេទចូលរួមដេញថ្លៃ |
|---|---|---|---|
| | ថ្ងៃទី ខែ ឆ្នាំ | ថ្ងៃទី ខែ ឆ្នាំ | ថ្ងៃទី ខែ ឆ្នាំ<br>វេលាម៉ោង ....... នាទីរសៀល |

- ❖ កន្លែងលក់ និងទទួលពាក្យស្នើសុំចូលរួមដេញថ្លៃ÷ នៅ.............................................. រៀងរាល់ថ្ងៃធ្វើការ ចាប់ពីម៉ោង ០៨:០០ នាទីព្រឹកដល់ម៉ោង ១២:០០ នាទី ថ្ងៃត្រង់ និងចាប់ពីម៉ោង ០២:០០ នាទីរសៀលដល់ម៉ោង ០៥:០០ នាទីល្ងាច។
- ❖ កន្លែង និងដំណើរការដេញថ្លៃ÷ នឹងប្រព្រឹត្តទៅ............................ តាមកាលបរិច្ឆេទដែលបានកំណត់ជូនខាងលើ។

*គណៈកម្មការ សូមរក្សាសិទ្ធិកែប្រែកាលបរិច្ឆេទ និងទីកន្លែងដែលបានជម្រាបជូនខាងលើ។*

ថ្ងៃ ខែ ឆ្នាំ ស័ក ព.ស.២៥៦

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

គណៈកម្មការជម្រះ និងលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះនៃ....

**ប្រធាន**

សូមទំនាក់ទំនង

១. លោក ........................

២. លោកស្រី ...................

ឧបសម្ព័ន្ធទី១÷ គំរូសេចក្តីជូនដំណឹងស្តីពីការប្រកាសដេញថ្លៃ និងចរចាពិគ្រោះថ្លៃ ខ-១
ភ្ជាប់នឹងប្រកាសលេខ៨៨៤.សហវ.ប្រក ចុះថ្ងៃទី..០២..... ខែ.មករា.. ឆ្នាំ.២០២០
ស្តីពី វិធាននិងនីតិវិធីលម្អិត នៃការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

## សេចក្តីជូនដំណឹង

## ស្តីពីការប្រកាសការចរចាពិគ្រោះថ្លៃទ្រព្យសម្បត្តិ(.........) ដែលត្រូវបានការអនុញ្ញាតជម្រះចេញពីបញ្ជីទ្រព្យសម្បត្តិរដ្ឋ

គណៈកម្មការជម្រះនិងលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះនៃ.........មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន មេត្តាជ្រាបថា គណៈកម្មការ នឹងធ្វើការចរចាពិគ្រោះថ្លៃជាកញ្ចប់ នូវ......................... (យថាប្រភេទនៃ.................................. មានបញ្ជាក់លម្អិតក្នុងតារាងភ្ជាប់) ដែលត្រូវបានជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ។

រូបវន្តបុគ្គល និងនីតិបុគ្គលទាំងអស់ អាចចូលរួមចរចាពិគ្រោះថ្លៃបានដោយត្រូវបំពេញសំណុំបែបបទ និងលក្ខខណ្ឌដូចមានចែងក្នុងសៀវភៅបន្ទុកចរចាពិគ្រោះថ្លៃ។

តម្លៃមូលដ្ឋាន និងកាលបរិច្ឆេទនៃដំណើរការចរចាពិគ្រោះថ្លៃមានដូចខាងក្រោម÷

| តម្លៃមូលដ្ឋាន | កាលបរិច្ឆេទ លក់ និង ទទួលពាក្យសុំ | កាលបរិច្ឆេទឈប់ ទទួលពាក្យសុំ | កាលបរិច្ឆេទចូលរួមចរចាពិគ្រោះថ្លៃ |
|---|---|---|---|
| | ថ្ងៃទី ខែ ឆ្នាំ | ថ្ងៃទី ខែ ឆ្នាំ | ថ្ងៃទី ខែ ឆ្នាំ វេលាម៉ោង ....... នាទីរសៀល |

- កន្លែងលក់ និងទទួលពាក្យស្នើសុំចូលរួមចរចាពិគ្រោះថ្លៃ÷ នៅ.................................................. រៀងរាល់ថ្ងៃធ្វើការ ចាប់ពីម៉ោង ០៨:០០ នាទីព្រឹកដល់ម៉ោង ១២:០០ នាទី ថ្ងៃត្រង់ និងចាប់ពីម៉ោង ០២:០០ នាទីរសៀលដល់ម៉ោង ០៥:០០ នាទីល្ងាច។
- កន្លែង និងដំណើរការចរចាពិគ្រោះថ្លៃ÷ នឹងប្រព្រឹត្តទៅ ............................. តាមកាលបរិច្ឆេទដែលបានកំណត់ជូនខាងលើ។

*គណៈកម្មការ សូមរក្សាសិទ្ធិកែប្រែកាលបរិច្ឆេទ និងទីកន្លែងដែលបានជម្រាបជូនខាងលើ។*

ថ្ងៃ ខែ ឆ្នាំ ស័ក ព.ស.២៥៦

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

គណៈកម្មការជម្រះ និងលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះនៃ....

**ប្រធាន**

សូមទំនាក់ទំនង÷

១. លោក ........................

២. លោកស្រី ..................

ឧបសម្ព័ន្ធទី២ ÷ គំរូពាក្យស្នើសុំចូលរួមដេញថ្លៃ និងចរចាពិគ្រោះថ្លៃ ក-២

ភ្ជាប់នឹងប្រកាសលេខ០៩២សហវ.ប្រកចុះថ្ងៃទី..០៦...... ខែ.មករា..ឆ្នាំ២០២០

ស្តីពី វិធាននិងនីតិវិធីលម្អិត នៃការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ពាក្យសុំចូលរួមដេញថ្លៃទិញទ្រព្យសម្បត្តិ (.............) ដែលត្រូវបានជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ**

**របស់ក្រសួង-ស្ថាប័ន/រដ្ឋបាលថ្នាក់ក្រោមជាតិ/នីតិបុគ្គលសាធារណៈ.......................**

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ .................................. ភេទ......... សញ្ជាតិ.................. ថ្ងៃខែឆ្នាំកំណើត .................. ទីកន្លែងកំណើត..............................................................................................កាន់អត្តសញ្ញាណប័ណ្ណ/ លិខិតឆ្លងដែនលេខ ..............................មុខរបរ.........................................តំណាងឱ្យក្រុមហ៊ុន/ សហគ្រាស.............................. ..............................ដែលមានអាសយដ្ឋាន........................................................................................... ...........................................................................................ទូរស័ព្ទលេខ..........................................។

**សូមគោរពជូន**

**ឯកឧត្តម/ លោកជំទាវ/ លោក/ លោកស្រី............**

**កម្មវត្ថុ÷** សំណើសុំចូលរួមដេញថ្លៃទិញទ្រព្យសម្បត្តិ (.................) ដែលត្រូវជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

**យោង÷**- សេចក្តីជូនដំណឹងលេខ................ ចុះថ្ងៃទី.........ខែ......... ឆ្នាំ......... ស្តីពីការដេញថ្លៃទិញទ្រព្យសម្បត្តិ(.........)

- សៀវភៅបន្ទុកលេខ........... ចុះថ្ងៃទី........... ខែ..........ឆ្នាំ......... ស្តីពីការដេញថ្លៃទិញទ្រព្យសម្បត្តិ (.........) ដែលត្រូវជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/ នាងខ្ញុំ សូមជម្រាបជូន ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ប្រធាន មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំមានបំណងចូលរួមដេញថ្លៃទិញទ្រព្យសម្បត្តិ(.........) ដែលមានតម្លៃមូលដ្ឋានចាប់ពី...... .............................................................................................................................................។

*<u>សូមជូនភ្ជាប់មកជាមួយនូវ÷</u>*

1. ពាក្យស្នើសុំចូលរួមដេញថ្លៃ — ចំនួន ០៣ ច្បាប់
2. អត្តសញ្ញាណប័ណ្ណសម្រាប់សញ្ជាតិខ្មែរ/ លិខិតឆ្លងដែនសម្រាប់ជនបរទេស (ថតចម្លង មានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) — ចំនួន ០៣ ច្បាប់
3. លិខិតបញ្ជាក់ប្រាក់កក់ធានាការដេញថ្លៃ ១០% នៃតម្លៃមូលដ្ឋានកំណត់ក្នុងសៀវភៅបន្ទុក — ចំនួន ០៣ ច្បាប់
4. លិខិតអះអាងប្រគល់ប្រាក់កក់ធានាការដេញថ្លៃ — ចំនួន ០៣ ច្បាប់
5. សៀវភៅបន្ទុកស្តីពីការដេញថ្លៃទិញទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះ — ចំនួន ០៣ ច្បាប់
6. កិច្ចសន្យាស្តីពីការអនុវត្តសៀវភៅបន្ទុក — ចំនួន ០៣ ច្បាប់
7. លិខិតប្រគល់សិទ្ធិ (ក្នុងករណីអ្នកតំណាង) — ចំនួន ០៣ ច្បាប់

ខ្ញុំបាទ/នាងខ្ញុំសូមសន្យាជាផ្លូវការថានឹងគោរពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ព្រមទាំងលក្ខខណ្ឌដូចមានចែងក្នុងសៀវភៅបន្ទុក និងកិច្ចសន្យាស្តីពីការអនុវត្តសៀវភៅបន្ទុក រួមទាំងកាតព្វកិច្ចសារពើពន្ធ និងមិនមែនសារពើពន្ធ ផងដែរ។

សូម ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ប្រធាន មេត្តាទទួលនូវសេចក្តីគោរព ពីខ្ញុំបាទ/ នាងខ្ញុំ

ធ្វើនៅ...................... ថ្ងៃទី.......... ខែ........... ឆ្នាំ.........

**ស្នាមមេដៃស្តាំ និងឈ្មោះអ្នកស្នើសុំដេញថ្លៃ**

## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

**ពាក្យសុំចូលរួមចរចាពិគ្រោះថ្លៃទិញទ្រព្យសម្បត្តិ (............) ដែលត្រូវបានជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង-ស្ថាប័ន/រដ្ឋបាលថ្នាក់ក្រោមជាតិ/នីតិបុគ្គលសាធារណៈ.....................**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ............................ ភេទ........ សញ្ជាតិ.................. ថ្ងៃខែឆ្នាំកំណើត .................
ទីកន្លែងកំណើត......................................................................កាន់អត្តសញ្ញាណប័ណ្ណ/ លិខិតឆ្លងដែនលេខ
............................ មុខរបរ.......................................តំណាងឱ្យក្រុមហ៊ុន/ សហគ្រាស.............................
............................ដែលមានអាសយដ្ឋាន...................................................................................
..................................................................................ទូរស័ព្ទលេខ......................................។

**សូមគោរពជូន**

**ឯកឧត្តម/ លោកជំទាវ/ លោក/ លោកស្រី...........**

**កម្មវត្ថុ÷** សំណើសុំចូលរួមចរចាពិគ្រោះថ្លៃទិញទ្រព្យសម្បត្តិ (................) ដែលត្រូវជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។
**យោង÷**- សេចក្តីជូនដំណឹងលេខ................ ចុះថ្ងៃទី.......ខែ.....ឆ្នាំ...... ស្តីពីការចរចាពិគ្រោះថ្លៃទិញទ្រព្យសម្បត្តិ(.........)
- សៀវភៅបន្ទុកលេខ............ ចុះថ្ងៃទី............ ខែ......ឆ្នាំ..... ស្តីពីការចរចាពិគ្រោះថ្លៃទិញទ្រព្យសម្បត្តិ (.........) ដែលត្រូវជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមជម្រាបជូន ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ប្រធាន មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំមានបំណងចូលរួមចរចាពិគ្រោះថ្លៃទិញទ្រព្យសម្បត្តិ (.........) ដែលមានតម្លៃមូលដ្ឋានចាប់ពី ......................................................................................................................................។

*<u>សូមផ្ញើភ្ជាប់មកជាមួយនូវ÷</u>*

1. ពាក្យស្នើសុំចូលរួមចរចាពិគ្រោះថ្លៃ ចំនួន ០៣ ច្បាប់
2. អត្តសញ្ញាណប័ណ្ណសម្រាប់សញ្ជាតិខ្មែរ/ លិខិតឆ្លងដែនសម្រាប់ជនបរទេស ចំនួន ០៣ ច្បាប់
(ថតចម្លង មានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច)
3. លិខិតបញ្ជាក់ប្រាក់កក់ធានាការចរចាពិគ្រោះថ្លៃ១០%នៃតម្លៃមូលដ្ឋានកំណត់ក្នុងសៀវភៅបន្ទុក ចំនួន ០៣ ច្បាប់
4. លិខិតអះអាងប្រគល់ប្រាក់កក់ធានាការចរចាពិគ្រោះថ្លៃ ចំនួន ០៣ ច្បាប់
5. សៀវភៅបន្ទុកស្តីពីការចរចាពិគ្រោះថ្លៃទិញទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះ ចំនួន ០៣ ច្បាប់
6. កិច្ចសន្យាស្តីពីការអនុវត្តសៀវភៅបន្ទុក ចំនួន ០៣ ច្បាប់
7. លិខិតប្រគល់សិទ្ធិ (ក្នុងករណីអ្នកតំណាង) ចំនួន ០៣ ច្បាប់

ខ្ញុំបាទ/នាងខ្ញុំសូមសន្យាជាផ្លូវការថានឹងគោរពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ព្រមទាំងលក្ខខណ្ឌដូចមានចែងក្នុងសៀវភៅបន្ទុក និងកិច្ចសន្យាស្តីពីការអនុវត្តសៀវភៅបន្ទុក រួមទាំងកាតព្វកិច្ចសារពើពន្ធ និងមិនមែនសារពើពន្ធ ផងដែរ។

សូម ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ប្រធាន មេត្តាទទួលនូវសេចក្តីគោរព ពីខ្ញុំបាទ/នាងខ្ញុំ

ធ្វើនៅ......................... ថ្ងៃទី........... ខែ........... ឆ្នាំ..........

**ស្នាមមេដៃស្តាំ និងឈ្មោះអ្នកស្នើសុំចរចាពិគ្រោះថ្លៃ**

ឧបសម្ព័ន្ធទី ៣÷ គំរូសៀវភៅបន្ទុកស្តីពីការដេញថ្លៃ និងចរចាពិគ្រោះថ្លៃ ក-៣
ភ្ជាប់នឹងប្រកាសលេខ[illegible]ចុះថ្ងៃទី...០៦....ខែ.មករា....ឆ្នាំ២០២០
ស្តីពី វិធាននិងនីតិវិធីលម្អិត នៃការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

# សៀវភៅបន្ទុក

## ស្តីពីការដេញថ្លៃលក់ទ្រព្យសម្បត្តិ (................)
## ដែលត្រូវជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
## រួមមាន.........................

កំពុងរក្សាទុកនៅ...................

រៀបចំដោយ

**គណៈកម្មការជម្រះ និងលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះ**

**នៃក្រសួង/ស្ថាប័ន/រដ្ឋបាលរាជធានី-ខេត្ត/នីតិបុគ្គលសាធារណៈ......**

(.........)ឆ្នាំ...........

## ជំពូកទី ១
## កម្មវត្ថុនៃសៀវភៅបន្ទុក

**ប្រការ ១.-**

សៀវភៅបន្ទុកនេះ មានគោលដៅកំណត់លក្ខខណ្ឌ និងនីតិវិធីសម្រាប់ការដាក់ដេញថ្លៃលក់ជាកញ្ចប់នូវទ្រព្យសម្បត្តិ(................) ដែលត្រូវជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរួមមាន.........................។

**ប្រការ ២.-**

ទ្រព្យសម្បត្តិ (................) ដែលត្រូវជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ សម្រាប់ដាក់ដេញថ្លៃជាសាធារណៈ មានលក្ខណៈដូចខាងក្រោម÷

ក. ជាទ្រព្យសម្បត្តិខូចគុណភាព ចាស់ទ្រុឌទ្រោម អស់សុពលភាពប្រើប្រាស់ ដោយមានគោលការណ៍អនុញ្ញាតអោយជម្រះពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលកំពុងរក្សាទុកនៅ.......។

ខ. យថាប្រភេទនៃទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះទាំងអស់ដែលត្រូវដាក់ដេញថ្លៃ មានបញ្ជាក់លម្អិតក្នុងតារាងដែលមានភ្ជាប់ជាឧបសម្ព័ន្ធនៃសៀវភៅបន្ទុកនេះ។

គ. ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះទាំងអស់ គឺត្រូវដាក់លក់ដេញថ្លៃជាកញ្ចប់ក្នុងតម្លៃមូលដ្ឋានមួយ ដែលជាកម្មវត្ថុនៃការដាក់ឱ្យដេញថ្លៃឡើង។

ឃ. តម្លៃមូលដ្ឋានសម្រាប់ដាក់ឱ្យដេញថ្លៃគឺ÷.......... ៛ (...............រៀលគត់)។

## ជំពូកទី ២
## ការផ្សព្វផ្សាយ ទីកន្លែង និងកាលបរិច្ឆេទ នៃការដេញថ្លៃ

**ប្រការ ៣.-**

ការផ្សព្វផ្សាយ ទីកន្លែង និងកាលបរិច្ឆេទ នៃការដេញថ្លៃ មានដូចតទៅ÷

១- សេចក្តីជូនដំណឹង ស្តីពីការដេញថ្លៃនឹងត្រូវផ្សព្វផ្សាយជាសាធារណៈ តាមរយៈសារព័ត៌មានមុនពេលដេញថ្លៃរយៈពេល ០២ (ពីរ) សប្តាហ៍។

២- កន្លែងលក់ និងទទួលពាក្យដេញថ្លៃ÷

- ការិយាល័យរដ្ឋបាល.................. (ក្នុងបរិវេណក្រសួងស្ថាប័ន......)
- តម្លៃលក់ឯកសារដេញថ្លៃ គឺ..................៛(............ រៀលគត់) ក្នុងមួយច្បាប់(រួមមានពាក្យសុំចូលរួមដេញថ្លៃ និងឧបសម្ព័ន្ធភ្ជាប់)។

៣- កាលបរិច្ឆេទចាប់ផ្តើមលក់ និងទទួលពាក្យដេញថ្លៃមានកំណត់ក្នុងសេចក្តីជូនដំណឹងរបស់គណៈកម្មការជម្រះនិងលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះនៃ..........។

៤- អ្នកមានបំណងដាក់ពាក្យចូលរួមដេញថ្លៃ អាចស្នើសុំទៅកាន់គណៈកម្មការជម្រះនិងលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះនៃ.......... តាមរយៈលេខទូរសព្ទដែលបានផ្តល់ជូនក្នុងសេចក្តីជូនដំណឹង ឬមន្ត្រី

មានសមត្ថកិច្ចនៅកន្លែងលក់ និងដាក់ពាក្យដេញថ្លៃ ដើម្បីទទួលបានកម្មវិធីចុះពិនិត្យទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះ ក្នុងអំឡុងពេលនៃកាលបរិច្ឆេទ លក់ពាក្យ និងទទួលពាក្យចូលរួមដេញថ្លៃ។

៥-កាលបរិច្ឆេទ និងទីកន្លែងដេញថ្លៃ ត្រូវបានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹង។

## ជំពូកទី ៣
## លក្ខខណ្ឌ និងនីតិវិធីនៃការដេញថ្លៃលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះ

**ប្រការ ៤.-**

ក-រូបវន្តបុគ្គល ឬនីតិបុគ្គល លើកលែងតែករណីដូចមានចែងក្នុងប្រការ៤ ត្រង់ចំណុច ខ និងចំណុច គ នៃសៀវភៅបន្ទុកនេះ ដែលមានសមត្ថភាពហិរញ្ញវត្ថុ អាចស្នើសុំចូលរួមដេញថ្លៃ ដោយត្រូវបំពេញសំណុំលិខិតដូចខាងក្រោម÷

១- ពាក្យស្នើសុំចូលរួមដេញថ្លៃ

២-អត្តសញ្ញាណប័ណ្ណសម្រាប់សញ្ជាតិខ្មែរ/លិខិតឆ្លងដែនសម្រាប់ជនបរទេស (ថតចម្លងដោយមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច)

៣-លិខិតបញ្ជាក់ប្រាក់កក់ធានាការដេញថ្លៃ ១០% នៃតម្លៃមូលដ្ឋានកំណត់ក្នុងសៀវភៅបន្ទុកដែលចេញដោយគណៈកម្មការជម្រះនិងលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះនៃ..........

៤-លិខិតអះអាងប្រគល់ប្រាក់កក់ធានាការដេញថ្លៃរបស់អ្នកចូលរួមដេញថ្លៃ

៥- សៀវភៅបន្ទុកស្តីពីការដាក់ដេញថ្លៃលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះ

៦- កិច្ចសន្យាស្តីពីការអនុវត្តសៀវភៅបន្ទុកដាក់ដេញថ្លៃលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះ

៧-លិខិតប្រគល់សិទ្ធិ (ក្នុងករណីអ្នកតំណាង)។

ខ-ត្រូវបានហាមឃាត់ការចូលរួមដេញថ្លៃនេះ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល ដូចខាងក្រោម÷

- រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលនៅជាប់បំណុលរដ្ឋ (រួមមាន បំណុលសារពើពន្ធ និងមិនមែនសារពើពន្ធ)
- រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលជាប់ពាក់ព័ន្ធនឹងបទល្មើសផ្សេងៗ។

គ-ក្រោយពេលដេញថ្លៃរួច ក្នុងករណីរកឃើញរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានឈ្នះការដេញថ្លៃស្ថិតក្នុងករណីណាមួយដូចមានចែងក្នុងប្រការ៤ ត្រង់ចំណុច ខ នៃសៀវភៅបន្ទុកនេះ គណៈកម្មការជម្រះនិងលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះនៃ..........មានសិទ្ធិលុបចោលលទ្ធផលដេញថ្លៃទោះបីបានប្រកាស ឬមិនទាន់បានប្រកាសលទ្ធផលជាផ្លូវការ និងមានសិទ្ធិចាត់ចែងដេញថ្លៃឡើងវិញ ឬ ប្រគល់ជ័យលាភី ជូនអ្នកដេញថ្លៃឈ្នះនៅលេខរៀងបន្ទាប់ ហើយប្រាក់កក់ធានាការដេញថ្លៃរបស់បុគ្គលដែលមានកំហុស ត្រូវរឹបអូសទុកជាថវិការដ្ឋ។

**ប្រការ ៥.-**

នីតិវិធីនៃការដេញថ្លៃ ត្រូវអនុវត្តដូចខាងក្រោម÷

១-គណៈកម្មការ ត្រូវពិនិត្យ និងវាយតម្លៃលើរាល់សំណុំលិខិតរបស់បេក្ខជន ដែលបានដាក់ពាក្យសុំចូលរួមដេញថ្លៃ ហើយប្រកាសឈ្មោះបេក្ខជនដែលត្រូវមានសិទ្ធិចូលរួមដេញថ្លៃ។

២-គណៈកម្មការ ត្រូវប្រកាសអំពីទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះ ដែលដាក់ជាមូលដ្ឋានសម្រាប់ការដេញថ្លៃឡើង និងលក្ខខណ្ឌលម្អិតផ្សេងទៀតដែលពាក់ព័ន្ធ។

៣-វិធីនៃការដេញថ្លៃគឺត្រូវអនុវត្តតាមរូបភាពនៃការដេញថ្លៃឡើងដោយដាក់ក្នុងស្រោមសំបុត្រជាសម្ងាត់ចំនួន០៣ លើកបន្តជាប់គ្នា÷

-**ដេញថ្លៃលើកទី១**: ត្រូវធ្វើឡើងដោយកំណត់យកតម្លៃមូលដ្ឋានសរុបចំនួន ........៛ ( ... រៀលគត់)

-**ដេញថ្លៃលើកទី២**: ការកំណត់តម្លៃមូលដ្ឋានដេញថ្លៃលើកទី២ ត្រូវធ្វើឡើងដោយកំណត់យកតម្លៃដែលអ្នកដេញបានខ្ពស់ជាងគេលើកទី១ ដេញថ្លៃឡើងបន្ថែមទៀត។

-**ដេញថ្លៃលើកទី៣**: ការកំណត់តម្លៃមូលដ្ឋានដេញថ្លៃលើកទី៣ ត្រូវធ្វើឡើងដោយកំណត់យកតម្លៃដែលអ្នកដេញបានខ្ពស់ជាងគេលើកទី២ ដេញថ្លៃឡើងបន្ថែមទៀត។

-អ្នកចូលរួមដេញថ្លៃអាចបន្តទៅវគ្គបន្តបន្ទាប់ទៀតបាន លុះត្រាតែបានដាក់តម្លៃស្មើ ឬលើសតម្លៃមូលដ្ឋានដេញថ្លៃនៃវគ្គនីមួយៗ។

៤-អ្នកចូលរួមដេញថ្លៃដែលបានឱ្យថ្លៃខ្ពស់ជាងគេចុងក្រោយនោះ ត្រូវបានទទួលស្គាល់ថាជាអ្នកឈ្នះការដេញថ្លៃបណ្តោះអាសន្ន តាមរយៈកំណត់ហេតុស្តីពីលទ្ធផលនៃការដេញថ្លៃ ដែលមានការឯកភាពពីប្រធានគណៈកម្មការ ឬដោយអ្នកតំណាងតាមរយៈការផ្ទេរសិទ្ធិរបស់ប្រធានគណៈកម្មការ។

៥-លទ្ធផលដេញថ្លៃ ត្រូវកត់ត្រាក្នុងកំណត់ហេតុស្តីពីលទ្ធផលនៃការដេញថ្លៃ ដែលមានការឯកភាពពីប្រធានគណៈកម្មការ ឬដោយអ្នកតំណាងតាមរយៈការផ្ទេរសិទ្ធិរបស់ប្រធានគណៈកម្មការ ។

៦-លទ្ធផលនៃការដេញថ្លៃ នឹងត្រូវប្រកាសជាផ្លូវការដោយប្រធានគណៈកម្មការយ៉ាងយូរ............ សប្តាហ៍ក្រោយពីកាលបរិច្ឆេទដេញថ្លៃ។

៧-អ្នកឈ្នះការដេញថ្លៃ ត្រូវបំពេញបែបបទចប់សព្វគ្រប់តាមនីតិវិធីជាធរមាន ដើម្បីទទួលបានសិទ្ធិជាម្ចាស់កម្មសិទ្ធិស្របច្បាប់។

## ជំពូកទី ៤
## ការបង់ប្រាក់កក់ធានាការដេញថ្លៃ និងការទូទាត់

**ប្រការ ៦._**

១-អ្នកចូលរួមដេញថ្លៃ ត្រូវបង់ប្រាក់កក់ធានាការដេញថ្លៃចំនួន ១០% (ដប់ភាគរយ) នៃតម្លៃមូលដ្ឋានស្មើនឹងចំនួន .....៛ ( ... រៀលគត់) នៅការិយាល័យរដ្ឋបាល.... (ក្នុងបរិវេណក្រសួងស្ថាប័ន......)។

២-ការិយាល័យរដ្ឋបាល............ (ក្នុងបរិវេណក្រសួងស្ថាប័ន......) ត្រូវចេញលិខិតទទួលប្រាក់កក់ធានាការដេញថ្លៃជូនអ្នកចូលរួម ដោយត្រូវមានចុះហត្ថលេខាពីប្រធានគណៈកម្មការ ។

៣-ប្រាក់កក់ធានាការដេញថ្លៃរបស់អ្នកចូលរួមដេញថ្លៃ ដែលដេញថ្លៃពុំបាន ត្រូវប្រគល់ជូនសាមីខ្លួនវិញនៅ ៧ (ប្រាំពីរ)ថ្ងៃ ក្រោយការដេញថ្លៃ ដោយភ្ជាប់មកជាមួយនូវសក្ខីប័ត្របង់ប្រាក់កក់ធានាការដេញថ្លៃ និងកំណត់ហេតុដេញថ្លៃដែលបញ្ជាក់ថា អ្នកចូលរួមដេញថ្លៃនោះពិតជាដេញថ្លៃពុំបានមែនដោយ មានការបញ្ជាក់ពី គណៈកម្មការជម្រះនិងលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះនៃ...។

**ប្រការ ៧.-**

អ្នកដេញថ្លៃឈ្នះ ត្រូវធ្វើការទូទាត់ថ្លៃ...... ដែលដេញថ្លៃឈ្នះ ដោយអនុវត្តតាមនីតិវិធីដូចខាងក្រោម÷

- ដំណាក់កាលទី១ : ត្រូវធ្វើការទូទាត់ថ្លៃ...... ដែលដេញថ្លៃឈ្នះទាំងស្រុងចំនួន ១០០% ដោយមិនអនុញ្ញាតឱ្យបង្គ្រប់លើប្រាក់កក់ធានាការដេញថ្លៃចំនួន១០%នោះទេ ដូចបានកំណត់ក្នុងប្រការ៦ ចំណុច១ ចូលទៅក្នុងគណនីរបស់អគ្គនាយកដ្ឋានរតនាគារជាតិ ឬសាខារតនាគាររាជធានី-ខេត្ត យ៉ាងយូរ ០៧ (ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយមានការបញ្ជាក់ក្នុងលិខិតប្រកាសលទ្ធផលស្ថាពរជាផ្លូវការ ចេញដោយគណៈកម្មការ។
- ដំណាក់កាលទី២ : ក្រោយពេលអ្នកដេញថ្លៃឈ្នះ បានធ្វើការទូទាត់ស្របទៅនឹងដំណាក់កាលទី១ រួចរាល់ គណៈកម្មការ ត្រូវចេញលិខិតបញ្ជាក់ឱ្យអ្នកដេញថ្លៃឈ្នះ ដកប្រាក់កក់ធានាការពិគ្រោះថ្លៃចំនួន១០% មកវិញ។

## ជំពូកទី ៥
## ការប្រគល់-ទទួល

**ប្រការ ៨.-**

១. បន្ទាប់ពីអ្នកដេញថ្លៃឈ្នះ បានធ្វើការទូទាត់ទាំងស្រុងស្របទៅនឹងប្រការ៧ គណៈកម្មការជម្រះ និងលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះនៃ... ត្រូវចេញលិខិតបញ្ជាក់ពីការផ្ទេរ និងគ្រប់គ្រង ............ឱ្យទៅអ្នកឈ្នះការដេញថ្លៃ ដើម្បីទទួលថែរក្សា ការពារទាំងបរិមាណ និងគុណភាពរបស់.............. ជាមួយនឹងសមត្ថកិច្ចពាក់ព័ន្ធ។

២. អ្នកដេញថ្លៃឈ្នះត្រូវដឹកជញ្ជូនចេញនូវ............... ដែលបានដេញថ្លៃឈ្នះឱ្យអស់ទាំងស្រុង ក្នុងរយៈពេល យ៉ាងយូរ០៧ (ប្រាំពីរ)ថ្ងៃ ចាប់ពីថ្ងៃទូទាត់។ ក្នុងករណីមានការយឺតយ៉ាវ គណៈកម្មការពុំទទួលខុសត្រូវលើការបាត់បង់ណាមួយឡើយ។

៣. ការចំណាយលើការស្នើសុំផ្ទេរកម្មសិទ្ធិ និងការបំពេញកាតព្វកិច្ចសារពើពន្ធ និងមិនមែនសារពើពន្ធនានាពាក់ព័ន្ធនឹង............... ដែលដេញថ្លៃឈ្នះ គឺជាបន្ទុករបស់អ្នកដែលដេញថ្លៃឈ្នះ។

៤. គណៈកម្មការ អាចសម្របសម្រួលក្នុងការផ្តល់ឯកសារនានាពាក់ព័ន្ធនឹងនីតិវិធីស្នើសុំផ្ទេរកម្មសិទ្ធិក្នុងករណីមានការស្នើសុំ។

## ជំពូកទី ៦
## វិវាទ

**ប្រការ ៩.-**

ករណីមានវិវាទក្នុងការអនុវត្តសៀវភៅបន្ទុកនេះ ភាគីពាក់ព័ន្ធទាំងអស់ ត្រូវចូលរួមពិភាក្សាដោះស្រាយជាមួយ គណៈកម្មការជម្រះនិងលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះនៃ...ក្នុងស្មារតីយោគយល់គ្នាជាមុនសិន។ ផុតរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីពេលមានវិវាទកើតឡើង ប្រសិនបើមិនអាចដោះស្រាយតាមរយៈការចរចាគ្នាទេ វិវាទនេះត្រូវបញ្ជូនទៅដោះស្រាយ ស្របតាមច្បាប់ និងក្រោមប្រព័ន្ធតុលាការនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**ប្រការ ១០.-**

ដើម្បីអនុវត្តសៀវភៅបន្ទុកនេះ ត្រូវមានកិច្ចសន្យាស្តីពីការអនុវត្តសៀវភៅបន្ទុកដាក់ដេញថ្លៃលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រុះ រវាង គណៈកម្មការជម្រុះនិងលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រុះនៃ..... និងអ្នកចូលរួមដេញថ្លៃដូចមានចែងក្នុងប្រការ៤ នៃសៀវភៅបន្ទុកនេះ។

**ប្រការ ១១.-**

ភាគីពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវរាល់បណ្តាប្រការ និងលក្ខខណ្ឌដែលមានចែងក្នុងសៀវភៅបន្ទុកនេះ ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា ដែលមានជាធរមាន ។

សៀវភៅបន្ទុកនេះ មានតម្កល់ទុកនៅ ÷

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ 0១ ច្បាប់
- គណៈកម្មការជម្រុះនិងលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រុះនៃ... 0១ ច្បាប់។

ថ្ងៃ ខែ ឆ្នាំ ....ស័ក ព.ស.២៥៦....

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

គណៈកម្មការជម្រុះនិងលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រុះនៃ...

**ប្រធាន**

ភ្ជាប់នឹងប្រកាសលេខ[illegible]ចុះថ្ងៃទី..០៦..... ខែ..មករា...ឆ្នាំ..២០២០

ស្តីពី វិធាននិងនីតិវិធីលម្អិត នៃការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

# សៀវភៅបន្ទុក

## ស្តីពីការចរចាពិគ្រោះថ្លៃលក់ទ្រព្យសម្បត្តិ (................)

## ដែលត្រូវជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

## រួមមាន.........................

